**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**

**លេខ/No: 002-19-09-2007 ECCC-OCIJ**

# ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន
## Provisional detention Order
## Ordonnance de placement en détention provisoire

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ

ឈ្មោះ **ខៀវ សំផន** ហៅ ហែម

កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១

ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ១៩៤៩ ដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រា៥ មាត្រា ៦ មាត្រា ២៩ ថ្មី និងមាត្រា ៣៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្ងៃទី២៧ តុលា ២០០៤។

បានឃើញការជជែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## ១- ស្ថានភាពអង្គហេតុ និង អង្គច្បាប់

១- នៅក្នុងករណីបច្ចុប្បន្ន (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ ដែលអាចអោយកំណត់ជាបទល្មើសផ្សេងទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និង ដែលអាចដាក់បន្ទុកលើជនត្រូវចោទ) **ឈ្មោះ ខៀវ សំផន** ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យអំពី ៖

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (អំពើមនុស្សឃាត ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការសំលាប់បំផុតពូជ និង អំពើអមនុស្សធម៌ដទៃទៀត) និង

- **បទឧក្រិដ្ឋសង្គ្រាម**ដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩ (អំពើមនុស្សឃាតដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើអោយឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និង សុខភាព ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និង ជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬ ជម្លៀស ឬ ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)

២- ជននេះត្រូវបានដាក់បន្ទុកថាបាន នៅលើទឹកដីនៃប្រទេសកម្ពុជាចន្លោះពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ១៩៧៩ ៖

- ក្នុងឋានៈជាប្រមុខរដ្ឋ (ប្រធាននៃគណៈប្រធានរដ្ឋ) ជាមេដឹកនាំនៅក្នុងមន្ទីរនយោបាយមជ្ឈិម (មន្ទីរ៨៧០) និង ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា

- ញុះញង់ ឬម្យ៉ាងទៀតបានសមគំនិតក្នុងការប្រព្រឹត្តបទល្មើសខាងលើ

- ដោយដឹកនាំ ជំរុញ ដាក់អោយដំណើរការ ឬ ផ្តល់ជំនួយក្រោមរូបភាពផ្សេងទៀតដល់នយោបាយ និង ការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចារឹកលក្ខណៈជា អំពើមនុស្សឃាត ការដាក់ឃុំឃាំង ការសំលាប់បំផុតពូជ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬ អំពើអមនុស្សធម៌ដទៃទៀតដូចជាការជម្លៀសដោយបង្ខំ ការដាក់ជាទាសករ ឬការធ្វើការដោយបង្ខំ

- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ និង ជាប្រព័ន្ធ សំដៅលើជនស៊ីវិល

- ដោយបញ្ជាក់ថា ក្នុងកំឡុងពេលទាំងអស់ ឬមួយផ្នែកនៃចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ ដល់ ថ្ងៃទី៦ មករា ១៩៧៩ កម្ពុជាប្រជាធិបតេយ្យ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាមបានស្ថិតនៅក្នុងស្ថានភាពនៃជំលោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា។

៣- សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញបានស្នើសុំឱ្យមានការឃុំខ្លួនបណ្តោះអាសន្នចំពោះ **ខៀវ សំផន** ដោយសំអាងថា មានហានិភ័យនៃការរត់គេចខ្លួនដោយសារតែជននេះមានលំនៅដ្ឋាននៅក្បែរព្រំដែនថៃ ហើយអាចនឹងត្រូវប្រឈមមុខនឹងការជាប់ឃុំឃាំងអស់មួយជីវិតផង។ ម្យ៉ាងទៀត ការរក្សាជននេះនៅក្រៅឃុំឃាំង[illegible]មាន

កំហឹងពីសំណាក់ជនរងគ្រោះ និង សាធារណៈជន (ដោយគូសបញ្ជាក់ថា ចាប់តាំងពីពេលដែលការចាប់ខ្លួនត្រូវបានធ្វើឡើង ចំនួននៃពាក្យបណ្តឹងចេះតែកើនឡើងជាលំដាប់) ហើយនឹងបង្កឲ្យមានហានិភ័យនៃចលាចលចំពោះសណ្តាប់ធ្នាប់-សាធារណៈ និង ការសងសឹក ដែលនាំអោយសន្តិសុខផ្ទាល់ខ្លួនរបស់ជននេះស្ថិតក្នុងសភាពគ្រោះថ្នាក់ ដូចអំពើហិង្សាដែលធ្លាប់កើតមានកាលពីឆ្នាំ ១៩៩១ នាពេលដែលជននេះចូលភ្នំពេញវិញ។ លើសពីនេះទៅទៀត សាក្សីភាគច្រើនគឺជាអតីតអ្នកនៅក្រោមបង្គាប់ **ខៀវ សំផន** និង មិនបានផ្តល់សក្ខីកម្មឡើយក្នុងករណីដែលជននេះមានសេរីភាព។ សហព្រះរាជអាជ្ញាក៏បានគូសបញ្ជាក់ផងដែរថា **ខៀវ សំផន** គឺជាប្រមុខរដ្ឋនៃរបបមួយដែលទទួលខុសត្រូវលើជនរងគ្រោះ ១,៧ លាននាក់ ហើយ វាជាការពិតដែលថាជននេះមិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែជននេះបានចូលរួមនៅក្នុងកិច្ចប្រជុំនោះ ។ ជននេះមិនដែលធ្លាប់ប្រកាស ឬ អន្តរាគមន៍ ទប់ស្កាត់ឧក្រិដ្ឋកម្មនានាឡើយ។

៤- **ខៀវ សំផន** ជំទាស់នឹងអង្គហេតុដែលដាក់បន្ទុកលើខ្លួន ដោយគូសបញ្ជាក់ថាសហព្រះរាជអាជ្ញាបានរំលឹកតែមុខងារដែលខ្លួនបានធ្វើតែប៉ុណ្ណោះ ដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ខ្លួនឡើយ។
ចំពោះតួនាទីពិតប្រាកដរបស់ខ្លួន ជនត្រូវចោទអះអាងថាខ្លួនមិនមានអំណាចអ្វីឡើយ។ ក្នុងនាមជាប្រធាននៃគណៈប្រធានរដ្ឋ ខ្លួនគ្រាន់តែមានតួនាទីតំណាងប៉ុណ្ណោះ ដែលស្រដៀងគ្នាទៅនឹងព្រះមហាក្សត្រនៃរបបបច្ចុប្បន្នដែរ។ ខ្លួនមិនធ្លាប់ជាប្រធានមន្ទីរ ៨៧០ ឡើយ ប៉ុន្តែធ្លាប់ត្រឹមតែជាសមាជិកធម្មតាទទួលបន្ទុករៀបចំបញ្ជីតម្លៃទំនិញប៉ុណ្ណោះ។ ជនត្រូវចោទបន្ថែមថា នៅក្នុងស្ថាប័ននេះ វិធានស្តីអំពីការសម្ងាត់គឺមានភាពតឹងរឹងបំផុត ៖ ម្នាក់ៗគិតតែអំពីការងាររបស់ខ្លួនតែប៉ុណ្ណោះ និង មិនដឹងអំពីការងាររបស់អ្នកដទៃនោះទេ។ ទាក់ទងនឹងឋានៈជាសមាជិកគណៈកម្មាធិការមជ្ឈឹមបក្ស ជនត្រូវចោទគូសបញ្ជាក់ថា រាល់សេចក្តីសម្រេចសំខាន់ៗត្រូវបានសម្រេចឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលខ្លួនមិនមែនជាសមាជិកឡើយ។ ជនត្រូវចោទទទួលស្គាល់ថាខ្លួនបានចូលរួមកិច្ចប្រជុំ“ដែលមានការពង្រីក”របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ប៉ុន្តែគូសបញ្ជាក់ថា នៅក្នុងនោះគេពិភាក្សាតែបញ្ហាទូទៅប៉ុណ្ណោះ ដូចជាការការពារជាតិ បញ្ហាទំនាក់ទំនងជាមួយវៀតណាម ឬ ការលាលែងរបស់សម្តេចព្រះនរោត្តមសីហនុ ដែលជាបញ្ហាដែលត្រូវតែដឹងដើម្បីអាចជម្រាបជូនទៅអ្នកការទូត ។ ជនត្រូវចោទលើកឡើងថា ដោយសារតែដើមកំណើតរបស់ខ្លួន គាត់ត្រូវបានគេមើលឃើញថាជាបញ្ញាជនស្នេហាជាតិ និង មិនអាចក្លាយជាមេបដិវត្តបាននោះទេ។ ទាក់ទងទៅនឹងអវត្តមានសេចក្តីថ្លែងការណ៍របស់ខ្លួនប្រឆាំងនឹងនយោបាយមេដឹកនាំខ្មែរក្រហម ជនត្រូវចោទបាននិយាយថា ខ្លួនបានជំនួសសម្តេចព្រះនរោត្តមសីហនុក្នុងឋានៈជាប្រមុខរដ្ឋនៅខែមេសា ឆ្នាំ ១៩៧៦។ មួយខែក្រោយមកគឺថ្ងៃទី ១៤ ឧសភា ១៩៧៦ “មានការដាក់ឱសានវាទពីវៀតណាមតាមរយៈការប្រើបញ្ហាព្រំដែនសមុទ្រ” ។ ជនត្រូវចោទអះអាងថា នៅក្នុងស្ថានភាពបែបនេះ ក្នុងនាមជាខ្មែរ ខ្លួនមិនអាចបើកមាត់ ដើម្បីឲ្យមានការបែកបាក់គ្នានោះទេ។ ជាសង្ខេបមក អំពីតួនាទីរបស់ខ្លួន ជនត្រូវចោទអះអាងថា គ្មានហេតុផលណាមួយដែលត្រូវសង្ស័យថាអ្នកនៅក្រោមបង្គាប់របស់ខ្លួនមិនបានធ្វើជាសាក្សីប្រឆាំងនឹងខ្លួនឡើយ ដោយ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ហេតុផលថាខ្លួនមិនមាន "អ្នកនៅក្រោមបង្គាប់" ឡើយ។ ជនត្រូវចោទបន្ថែមទៀតថា "*នៅក្នុងស្ថានភាពបច្ចុប្បន្ន វាអាចថាមនុស្សទាំងឡាយចង់ធ្វើជាសាក្សីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមណាមួយគឺដើម្បីទទួលបាននូវផលប្រយោជន៍*"។ ពាក់ព័ន្ធនឹងទឡ្ហីករណ៍ដែលលើកឡើងដោយសហព្រះរាជអាជ្ញាដើម្បីជាសំអាងដល់ការឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទប្រកាសថាខ្លួនមិនដែលមានចេតនារត់គេចខ្លួននោះទេ ហើយថា ហានិភ័យនៃចលាចលចំពោះសណ្ដាប់ធ្នាប់សាធារណៈក៏មិនមានដែរ ដោយគូសបញ្ជាក់ថា ចាប់តាំងពីឆ្នាំ ១៩៩៨ នៅពេលចុះចូលជាមួយរដ្ឋាភិបាល ខ្លួនបានរស់នៅក្នុងផ្ទះជាច្រើននៅប៉ៃលិនដោយគ្មានការការពារជាពិសេសអ្វីឡើយ ។ ផ្ទុយទៅវិញ នាពេលដែលខ្លួនមានបញ្ហាសុខភាពនាពេលថ្មីៗនេះ គ្រប់គ្នាបានមកផ្ទះខ្លួនដើម្បីជួយខ្លួន ហើយព្រឹត្តការណ៍កាលពីឆ្នាំ ១៩៩១ ដែលខ្លួនជាជនរងគ្រោះ វាកើតឡើងក្នុងបរិបទពិសេសមួយ គឺការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបញ្ហានយោបាយបានជ្រៀតជ្រែកចូលក្នុងរឿងនេះ ។ វាមិនមែនជាការស្អប់ខ្ពើមខ្លួនគាត់ឡើយ។

តាមរយៈធាតុទាំងនេះ ដោយផ្អែកលើសច្ចរណ៍នៃនិរទោស និង ដោយរំលឹកអំពីគោលការណ៍ដែលថាការមានសេរីភាពគឺជាគោលការណ៍ ហើយការឃុំខ្លួនបណ្ដោះអាសន្នគឺជាអញ្ញត្រកម្ម ជនត្រូវចោទស្នើសុំនៅក្រៅឃុំ។

## ២- សំអាងហេតុសេចក្ដីសម្រេច

៥- តាមរយៈឯកសារ និង ចម្លើយសាក្សីជាច្រើនដែលមាននៅក្នុងសំណុំរឿង មានហេតុផលនានាដែលអាចអោយជឿជាក់ថា **ខៀវ សំផន** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន ហើយជាពិសេស ក្នុងនាមជាមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ និង ជាប្រមុខរដ្ឋ **ខៀវ សំផន** បានអនុវត្តអំណាចជាក់ស្ដែង ដែលអាចឱ្យមើលឃើញពីខាងក្រៅទាំងនៅក្នុងប្រទេសកម្ពុជា និង នៅបរទេស។ ម្យ៉ាងវិញទៀត តាមរយៈអំពើរបស់ **ខៀវ សំផន** ដូចជា ការធ្វើសុន្ទរកថា ការអប់រំផ្នែកនយោបាយដែលជននេះបានធ្វើ ការយល់ព្រមជាសាធារណៈរបស់ខ្លួនចំពោះនយោបាយនៃរបប និង ការប្រកែករបស់ខ្លួននៅលើឆាកអន្តរជាតិថាមិនមានឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត (ដែលជននេះបានដឹងយ៉ាងច្បាស់អំពីឧក្រិដ្ឋកម្មនេះ) **ខៀវ សំផន** បានសម្របសម្រួល និង បានផ្ដល់ធម្មានុរូបភាពក្នុងកម្រិតខ្ពស់បំផុតដល់ការប្រព្រឹត្តអំពើឧក្រិដ្ឋដែលចេះតែបន្តនៅលើទឹកដីប្រទេសកម្ពុជាទាំងមូល។

៦- អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល ៣០ ឆ្នាំ ក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះវាមិនមែនជាការហួសហេតុពេកដែលអះអាងថានៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឱ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឱ្យមានអំពើហិង្សា ឬ អាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ម្យ៉ាងវិញទៀត ស្ថានភាពមិនអាចមើលឃើញជាក់ច្បាស់ដូចគ្នាទេរវាងពេលមុនការចោទប្រកាន់ និងក្រោយពេលចោទប្រកាន់ជាផ្លូវការនោះ។

៧- សម្រាប់បន្តការស៊ើបសួរ ជាការចាំបាច់ណាស់ដែលត្រូវបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ។ ដូចនេះ មានការភ័យខ្លាចថាប្រសិនបើអនុញ្ញាត្តិអោយនៅក្រៅឃុំ ជនត្រូវចោទព្យាយាម និង រៀបចំធ្វើការដាក់សម្ពាធបែបនេះ។ ម្យ៉ាងវិញទៀត **ខៀវ សំផន** នឹងមានសិទ្ធិពិនិត្យសំណុំរឿងស៊ើបសួរទាំងមូលដែលរួមមានជាពិសេសកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីនេះ ប្រសិនបើប្រភេទអង្គហេតុធ្វើអោយជនសង្ស័យពិបាកក្នុងការរកអត្តសញ្ញាណ និងជះឥទ្ធិពលលើសាក្សីសំខាន់ៗនោះ ចំនុចនេះលែងចោទជាបញ្ហាដល់ជនត្រូវចោទហើយនៅពេលដែលជននេះដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុក និង ជនរងគ្រោះដែលពាក់ព័ន្ធដោយនីតិវិធី។ ប្រឈមមុខនឹងស្ថានភាពថ្មីនេះ មានយុត្តិកម្មបញ្ជាក់ជាពិសេសដល់ការភ័យខ្លាចក្នុងការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះនេះ។

៨- ភាពធ្ងន់ធ្ងរជាពិសេសនៃបទល្មើសដែលចោទប្រកាន់លើ **ខៀវ សំផន** នាំអោយឃើញហានិភ័យខាងលើកាន់តែច្បាស់ថែមទៀត និង មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយទោះមានលក្ខណៈតឹងរ៉ឹងយ៉ាងណា ដែលមានប្រសិទ្ធិភាពអាចធានាអោយមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ ហើយថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចគោលដៅខាងលើនេះ។

៩- ជាផលវិបាក យល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានសារៈសំខាន់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ និង មានភាពចាំបាច់ផងដែរដើម្បីធានារក្សាទុកវត្តមានជនត្រូវចោទសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ និង ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ និង ដើម្បីការពារសុវត្ថិភាពផ្ទាល់របស់ជននេះ។

## ហេតុដូច្នេះ សម្រេច

សម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **ខៀវ សំផន** ចំនួនរយៈពេលអតិបរមា ១ ឆ្នាំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-Juges d'instruction**

MARCEL Lemonde **យូ ប៊ុនឡេង**

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសផងដែរ។

យើង........................................បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី.......ខែ.......... ឆ្នាំ..........

**ជនត្រូវចោទ    មេធាវីជនត្រូវចោទ    សហព្រះរាជអាជ្ញា    ការិយាល័យរដ្ឋបាល    អ្នកប្រគល់**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់រៀងរាល់ ១២០ ថ្ងៃម្តង ហើយ ត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្តការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅសហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION
E.C.C.C * C.E.T.C



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.